- ○ បានផ្សព្វផ្សាយសេចក្តីណែនាំលេខ ១៨ អយកសណាន ចុះថ្ងៃទី.២៤ មិថុនា ឆ្នាំ ២០១៣ ស្តីពីការលើកកម្ពស់សុវត្ថិភាពចំណីអាហារ និង អាហារប្រកបដោយសុខភាពនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និង ឯកជន
- ○ បានផ្សព្វផ្សាយសេចក្តីណែនាំលេខ ៣៣ អយកសណាន ចុះថ្ងៃទី. ២០ ខែ កក្កដា ឆ្នាំ ២០១៦ ស្តីពីការបន្តការអនុវត្តកម្មវិធីសិក្សាពីប្រធានបទការអប់រំសុខភាព នៅតាមគ្រឹះស្ថានបឋមសិក្សាមធ្យមសិក្សាចំណេះទូទៅ និង អប់រំបច្ចេកទេស

-ការប្រែប្រួលគុណភាពនៃសេវាអប់រំៈ

- ▪ លទ្ធផលនៃការសិក្សាៈ
  - ○ សាលាបានរៀបចំអនុវត្តកម្មវិធីសិក្សាពីប្រធានបទការអប់រំសុខភាព នៅតាមគ្រឹះស្ថានបឋមសិក្សាមធ្យមសិក្សាចំណេះទូទៅនិង អប់រំបច្ចេកទេស

-អត្រាឆ្លងភូមិសិក្សាៈ(គ្មាន)

-លទ្ធផលនៃការប្រឡងសញ្ញាបត្រៈ(គ្មាន)

-ការប្រឡងប្រណាំងសិស្សពូកែថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិៈ(គ្មាន)

- ▪ បរិស្ថានសិក្សាៈ
  - ○ បានចូលរួមធ្វើពលកម្មសម្អាតបរិស្ថានក្នុងក្រុមពោធិ៍សាត់បានចំនួន ៥ លើក
  - ○ បានប្រារព្ធទិវាកុមារអន្តរជាតិ ០១ មិថុនា លើកទី ៦៨ មានអ្នកចូលរួមសរុប ៣៦,០៩៦ នាក់ ស្រី ១៨,០៤៨ នាក់
- ▪ សម្ភារៈសិក្សាៈ(គ្មាន)
- ▪ ម៉ោងនិងកម្មវិធីសិក្សាៈ(គ្មាន)
- ▪ គុណវុឌ្ឍិរបស់គ្រូបង្រៀនៈ(គ្មាន)

-បញ្ហាប្រឈមទាក់ទងនឹងគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ

- ▪ ប្រសិទ្ធភាពនៃសេវាអប់រំ
  - ○ ពុំមានថវិកាសម្រាប់បើកវគ្គបំប៉នស្តីពីដំណើរការក្រុមប្រឹក្សាយុវជនកុមារ
  - ○ ពុំមានថវិកាសម្រាប់បើកវគ្គការយល់ដឹងអំពីសហគ្រិនភាពភាពដល់មន្ត្រីគ្រប់គ្រងមជ្ឈមណ្ឌលថ្នាក់ក្រុង/ស្រុក
  - ○ ពុំមានឯកសារគ្រប់គ្រាន់ និង គ្រូមុខវិជ្ជាសុខភាពសិក្សាដោយឡែកសម្រាប់បង្រៀនកម្មវិធីសិក្សាពីប្រធានបទការអប់រំសុខភាព នៅតាមគ្រឹះស្ថានបឋមសិក្សាមធ្យមសិក្សាចំណេះទូទៅ

- គុណភាពនៃសេវាអប់រំ
  - សាលាមួយចំនួននៅពុំទាន់មានផែនការ ការប្រជុំគណៈកម្មាធិការប្រតិបត្តិយុវជន កុមារ
  - គ្រូទទួលថ្នាក់ និង គ្រូតាមមុខវិជ្ជាពុំសូវចូលរួមក្នុងសកម្មភាពក្រុមប្រឹក្សាយុវជន កុមារ
  - គណៈកម្មាធិការប្រតិបត្តក្រុមប្រឹក្សាយុវជនតាមសាលានៅមានកម្រិតក្នុងការដឹកនាំក្រុម

**ខ-ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

-ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានផ្តោតលើលទ្ធផលៈ មន្ទីរអប់រំ យុជន និងកីឡាខេត្ត ដែលមានការិយាល័យយុវជនជាសេនាធិការបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង តួនាទីភារកិច្ចទទួលខុសត្រូវរបស់ការិយាល័យ និងអនុវត្តសេចក្តីណែនាំផ្សេងៗរបស់ក្រសួងនៃរាជរដ្ឋាភិបាល។ កាពិនិត្យតាមដានដោយផ្តោតទៅលើសកម្មភាពក្រុមប្រឹក្សាយុវជន និងកុមារ ការប្រជុំប្រចាំខែដោយផ្អែកទៅលើសកម្មភាពរបស់យុវជន តាមរយៈការបណ្តុះបណ្តាលជំនាញទន់សម្រាប់យុវជនការតម្រង់ទិសការសិក្សា ការងារ និង ការធ្វើសកម្មភាពជាក្រុម។

-ការអភិវឌ្ឍសមត្ថភាព

| សកម្មភាព | រយៈពេល | ទីកន្លែង | អ្នកចូលរួម | អ្នកឧបត្ថម្ភ |
|---|---|---|---|---|
| ១.វគ្គបំប៉នស្តីពី ពិនិត្យឡើងវិញលើវិស័យលើកកម្ពស់សុខភាពសិក្សា | ០១ថ្ងៃ | រាជធានីភ្នំពេញ | ២ នាក់ | ដៃគូរគាំទ្រវិស័យអប់រំទី ២ (ESDP2) |
| ២.វគ្គបណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍន៍សហគ្រាសតាមសហគមន៍ (C-BED) | ៣ ថ្ងៃ | ខេត្តសៀមរាប | ២ នាក់ | នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល |
| ៣.សិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោលស្តីពី សិទ្ធិរបស់យុវជននៅកន្លែងការងារ | ៣ ថ្ងៃ | ខេត្តបាត់ដំបង | ១ នាក់ | គម្រោងទីភ្នាក់ងារជាតិនិងមុខរបរ |
| ៤.បានដឹកនាំប្រតិភូកុមារទៅចូលរួមកម្មវិធីទស្សនកិច្ចសិក្សា ដើម្បីស្វែងយល់ពីវប្បធម៌ អរិយធម៌ ទស្សនាប្រាង្គប្រាសាទនានា | ៣ ថ្ងៃ | ខេត្តសៀមរាប | ១ នាក់ | ក្រសួងអប់រំ |
| ៥.សិក្ខាសាលាផ្សព្វផ្សាយគោល | | ខេត្ត | ១ នាក់ | អង្គការ |

| | | | | |
|---|---|---|---|---|
| ការណ៍ណែនាំអនុវត្តពីលក្ខខណ្ឌអប្បបរមាស្តីពី ទឹកស្អាត និងអនាម័យនៅតាមគ្រឹះស្ថានសិក្សា | ១ ថ្ងៃ | ព្រះសីហនុ | | UNICEF |
| ៦.វគ្គបណ្តុះបណ្តាលស្តីពី តួនាទីភារកិច្ច និងក្របខណ្ឌការងារសុខភាពសិក្សា ការលើកផែនការសកម្មភាព និងពិនិត្យតាមដាននិងវាយតម្លៃការងារសុខភាពសិក្សា | ០៣ ថ្ងៃ | ខេត្តកំពង់ចាម | ១ នាក់ | នាយកដ្ឋានសុខភាពសិក្សា |

## ៣.តារាងសូចនាករ និងចំណុចដៅរបស់អនុវិស័យយុវជន ឆ្នាំ២០១៧

| លរ. | សូចនាករផលសម្រេច | ជាក់ស្តែង **2016-2017** | ចំណុចដៅ **2017-2018** | ជាក់ស្តែង **2017-2018** | ស្ថានភាព |
|---|---|---|---|---|---|
| គោលនយោបាយទី ១ ៖ ធានាការអប់រំប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | |
| ១ | ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាលជំនាញខ្លីៗ | 0 | 20 | 0 | 0 |
| ២ | ចំនួនយុវជនដែលបានទទួលបានការបណ្តុះបណ្តាលពីការងារស្ម័គ្រចិត្ត | 0 | 8 | 0 | 0 |
| ៣ | ចំនួនមជ្ឈមណ្ឌលយុវជន | 1 | 1 | 1 | ⬆ |
| ៤ | ចំនួនយុវជនដែលបានបង្កើតការងារដោយខ្លួនឯងក្នុងមួយមជ្ឈមណ្ឌលក្នុងមួយឆ្នាំ | 0 | 100 | 0 | 0 |
| ៥ | ភាគរយសិស្សថ្នាក់ទី៤-៩ ចូលរួមក្នុងក្រុមប្រឹក្សាកុមារ | 77.6% | 85.0% | 77.6% | ⬇ |
| ៦ | ភាគរយសិស្សថ្នាក់ទី១០-១២ ចូលរួមក្នុងក្រុមប្រឹក្សាយុវជន | 100% | 100% | 100% | ⬆ |
| ៧ | ចំនួនយុវជនដែលបានទទួលបានការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងសហគ្រិនភាព | 0 | 21 | 0 | 0 |
| គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និង គ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | |
| | N/A | N/A | N/A | N/A | N/A |

សម្គាល់: ⬆ សម្រេចបានតាមចំណុចដៅ ➡ អាចទទួលយកបាន ⬇ សម្រេចមិនបានតាមចំណុចដៅ

តាមតារាងខាងលើបង្ហាញថាសូចនាករចំនួន ០២សម្រេចតាមចំនុចដៅ និង សូចនាករចំនួន០១ មិនអាចសម្រេចបានតាមគោលដៅ ហើយសូចនាករចំនួន ០៤ មិនបានអនុវត្តដោយមិនមានថវិកា។

### ៤. បញ្ហាប្រឈម

- ការចូលរួមរបស់សិស្សក្នុងការទិញអាវកាយរឹទ្ធិមានការពិបាក
- ខ្វះថវិកាគាំទ្រក្នុងការដឹកនាំយុវជនធ្វើសកម្មភាពសង្គម
- ការប្រជុំបូកសរុបវាយតម្លៃចលនាប្រឡងប្រណាំង ៣ ល្អ ថ្នាក់ខេត្ត និង ក្រុង ស្រុកពុំមានថវិកាសម្រាប់អនុវត្ត តាមការណែនាំរបស់ក្រសួង ។
- សាលាបឋមសិក្សា និងមធ្យមសិក្សាចំនួន ៨០ នៅមិនទាន់បង្កើតរចនាសម្ព័ន្ធ ក្រុមប្រឹក្សាកុមារពិសេសសាលាមិនគ្រប់កម្រិត និងសាលាដែលទើបតែបង្កើតថ្មី
- សាលាមួយចំនួននៅពុំទាន់មានផែនការ ការប្រជុំគណៈកម្មាធិការប្រតិបត្តិយុវជន កុមារ
- ពុំមានអគាររដ្ឋបាលមជ្ឈមណ្ឌលយុវជនខេត្ត
- គ្រូឈប្ថាក់ និងគ្រូតាមមុខវិជ្ជាពុំសូវចូលរួមក្នុងសកម្មភាពក្រុមប្រឹក្សាយុវជនកុមារ
- គណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាយុវជនតាមសាលានៅមានកម្រិតក្នុងការ ដឹកនាំក្រុម

### ៥. សេចក្តីសន្និដ្ឋាន

ឆ្នាំសិក្សា ២០១៦-២០១៧ នេះការអភិវឌ្ឍយុវជនមានការរីកចម្រើនគួរឱ្យគត់សំគាល់ដូចជា យុវជន ទទួលការបណ្តុះបណ្តាលជំនាញទន់ស្តីពី យល់ដឹងពីការងារស្ម័គ្រចិត្ត និង ភាពជាអ្នកដឹកនាំ ការរៀបចំបណ្តាញយុវជនស្ម័គ្រចិត្តថ្នាក់ ក្រុង ស្រុក ការយល់ដឹងពីអាហារូបត្ថម្ភ សុវត្ថិភាពចំណីអាហារ និង មានការយល់ដឹងច្បាស់លាស់ពីបំណិនជីវិតស្តីពី សុខភាពបន្តពូជ សុខភាពផ្លូវភេទ គ្រឿងញៀនសុខភាពអនាម័យ គ្រោះថ្នាក់ចរាចរ។ ជាមួយនេះដែរគណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាយុវជន កុមារ មានប្រវត្តិរូបច្បាស់លាស់ ប័ណ្ណសំគាល់ និង មានការស្ម័គ្រចិត្តពីសំណាក់សិស្សានុសិស្សក្នុងចលនាកាយរឹទ្ធិជាតិកម្ពុជា កាកបាទក្រហម ។

## ២.៦ អនុវិស័យអប់រំកាយ និង កីឡា

ពិនិត្យជារួមវិស័យអប់រំកាយ និងកីឡា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។ក្នុងឆ្នាំ ២០១៦-២០១៧កន្លងមកនេះ យើងបានរៀបចំប្រកួតកីឡាសិស្សជ្រើសរើសជើងឯកថ្នាក់

ស្រុក/ខេត្ត-មហាជនថ្នាក់ខេត្ត សហការរៀបចំប្រកួតកីឡាបានចំនួន ១០ កម្មវិធីពិសេស រៀបចំប្រកួតកីឡារត់ចម្ងាយស្ទឹង ។ ការិយាល័យអប់រំកាយ និងកីឡាបានរៀបចំក្រុមការងារ ចុះជួយសហការលើការងារបច្ចេកទេស និងបើកវគ្គសិក្ខាសាលាបានចំនួន១លើក នៅស្រុកភ្នំក្រវាញ ព្រមទាំងបានកែលម្អទីលានកីឡាតាមសាលា-សហគម ដើម្បីបម្រើដល់ការហ្វឹកហាត់ និងប្រកួត ។

## ក-ធានាការអប់រំឱ្យមានគុណភាពប្រកបដោយសមធម៌ និង បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

-ការប្រែប្រួលស្ថានភាពអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធអប់រំ:

- ខេត្តពោធិ៍សាត់មានទីលានបាល់ទាត់ ០២ កន្លែង បាល់ទះ ០២ កន្លែង ទីលានលោតកម្ពស់, ចំងាយ, ទីធ្លាសម្រាប់ហាត់អប់រំកាយគ្រប់សាលា លើកលែងទីលានបាល់បោះមិនទាន់មាន។

-ការប្រែប្រួលស្ថានភាពផ្គត់ផ្គង់បុគ្គលិកអប់រំ:

- គ្រូកីឡានៅសាលាមធ្យមសិក្សាចំនួន ២៧ បានរៀបចំកម្មវិធីបង្ហាត់ អប់រំកាយ និងកីឡាបានត្រឹមត្រូវ ។

-ការប្រែប្រួលស្ថានភាពចូលរៀនរបស់សិស្សានុសិស្ស:

- សិស្សានុសិស្សនៅសាលាបឋមសិក្សា និង មធ្យមសិក្សាមានការចាប់អារម្មណ៍ ចូលចិត្ត និង ចូលរួមសកម្មភាពអប់រំកាយ និងកីឡា។

-បញ្ហាប្រឈមទាក់ទង នឹងការទទួលសេវាអប់រំ

- ការផ្តល់សេវាអប់រំ:
  - ការផ្សព្វផ្សាយអប់រំកាយ និងកីឡាមិនទាន់បានទូលំទូលាយ
  - សាលាភាគច្រើនមិនមានគ្រូអប់រំកាយ និងកីឡា
- ការទទួលសេវាអប់រំ:
  - មាតាបិតាសិស្សមិនទាន់យល់ពីអត្ថប្រយោជន៍នៃការងារអប់រំកាយ និងកីឡា
  - កុមារីដែលនៅតាមសាលាតំបន់ជនបទមានការខ្មាស់អៀនច្រើនលើសកម្មភាពហាត់កីឡា

-ការប្រែប្រួលផ្នែកប្រសិទ្ធភាពផ្ទៃក្នុង៖

- អត្រាលំហូរសិស្ស (គ្មាន)
- ការអនុវត្តសេចក្តីណែនាំនានា:

- ○ បានផ្សព្វផ្សាយលិខិតលេខ ៧៩៣៩ អយក.អកសន របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៧ស្តីពី កម្មវិធីប្រកួតកីឡាសិស្សបឋមសិក្សា មធ្យមសិក្សា និង និស្សិត ដល់ក្រុង ស្រុកទាំង ០៦ ។
- ○ មន្ទីរអប់រំ យុវជននិងកីឡាបានចេញ លិខិតជូនដំណឹងលេខ ២៧៦៨/ ១២ អយក.ពសចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីកម្មវិធីប្រកួតកីឡាសិស្ស បឋមសិក្សា និង មធ្យមសិក្សា ជ្រើសរើសជើងឯកថ្នាក់ខេត្ត សម្រាប់ឆ្នាំសិក្សា ២០១៦-២០១៧ ។

- ការប្រែប្រួលគុណភាពនៃសេវាអប់រំះ (គ្មាន)
- ការប្រកួតកីឡាសិស្សថ្នាក់ស្រុក ថ្នាក់ខេត្ត:
  - ○ មានការប្រកួតកីឡាថ្នាក់ស្រុកលើវិញ្ញាសា បាល់ទាត់ បាល់ទះ បាល់បោះ និង អត្តពលកម្មទាំង ០៦ក្រុង ស្រុកមានចំនួន ២០៣ក្រុម កីឡាករ កីឡាការិនីសរុបចំនួន ២,៩៥២ កីឡាការិនី ចំនួន ១,០៦៨នាក់
  - ○ មានការប្រកួតកីឡាថ្នាក់ខេត្តលើវិញ្ញាសា បាល់ទាត់ បាល់ទះ បាល់បោះ និង អត្តពលកម្មមានចំនួន ១០៨ក្រុម កីឡាករ
  - ○ កីឡាការិនីសរុបចំនួន ១,៥៣០ នាក់ កីឡាការិនីចំនួន ៦៤២នាក់
  - ○ ចូលរួមប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិនៅមណ្ឌលរាជធានីភ្នំពេញលើវិញ្ញាសា បាល់ទាត់ បាល់ទះនិង អតពលកម្មមានចំនួន ០៣ ក្រុម កីឡាករ កីឡាការិនីសរុបចំនួន ៤២នាក់ កីឡាការិនីមានចំនួន ២១ នាក់ទទួលបានលទ្ធផលមេដាយ សំរិទ្ធ(បាល់ទះ)
  - ○ ចូលរួមប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិនៅមណ្ឌលខេត្តកំពង់ចាម លើវិញ្ញាសា បាល់ទាត់ បាល់ទះ បាល់បោះ និង អត្តពលកម្មមានចំនួន ០៧ ក្រុម កីឡាករ កីឡាការិនីសរុបចំនួន ៩៦ នាក់ កីឡាការិនីមានចំនួន ៤៨ នាក់ទទួលបានលទ្ធផលមេដាយមាសចំនួន ០២ គ្រឿង និង មេដាយប្រាក់ ០១ គ្រឿង(អត្តពលកម្ម)។

▪ បរិស្ថានសិក្សា:
  - ○ មានការកែលម្អទីលានកីឡដ្ឋានខេត្ត និង ដាក់ឱ្យប្រើប្រាស់ក្នុងការ ប្រកួត និង ហ្វឹកហាត់ មានដូចជា ទីលានបាល់ទាត់ ០១ កន្លែង បាល់បោះ ០១ កន្លែង បេតង់ ០១ កន្លែង និង មានទីលាន អត្តពលកម្មមាន ០៣ កន្លែង។
  - ○ បានជួសជុលទីលានបាល់ទាត់០១ កន្លែង នៅវិទ្យាល័យឈើតុំស្រុកក្រគរ។

- សម្ភារៈហ្វឹកហាត់: សាលាមធ្យមសិក្សាចំនួន ៥៩ បានទទួលសម្ភារ បាល់ទាត់ បាល់ទះ បាល់បោះ និង សម្ភារអត្តពលកម្ម (ស្នូរ ដុំដែក ប៊ូល...) សម្រាប់ការហ្វឹកហាត់របស់សិស្ស ។
- ម៉ោងនៃការសិក្សា:
  - អនុវត្តម៉ោងនៃកម្មវិធីអប់រំកាយ និង សុខភាពនៅសាលាបឋមសិក្សា បានចំនួន ៨៣ ម៉ោង ស្មើ ៦០ ភាគរយ
  - អនុវត្តម៉ោងនៃកម្មវិធីអប់រំកាយ និង កីឡា នៅសាលាមធ្យម សិក្សា បានចំនួន ៨៥ ម៉ោង ស្មើ ៦៣ ភាគរយ
- កម្មវិធីសិក្សា:
  - ការអនុវត្តកម្មវិធីសិក្សាអប់រំកាយ និង សុខភាព នៅសាលាបឋមសិក្សាមានដំណើរការដោយគ្រូឈរថ្នាក់។
  - ការអនុវត្តកម្មវិធីសិក្សាអប់រំកាយ និង កីឡា នៅសាលា មធ្យមសិក្សា មានដំណើរការ ២៧សាលា លើសាលា ៥៩។
- គុណវុឌ្ឍិរបស់គ្រូបង្រៀន:
  - មន្ត្រីអប់រំកាយ និងកីឡា មានចំនួន ១៥ នាក់ ស្រី ០៤ នាក់ បានចូលរួមបណ្តុះបណ្តាលថ្នាក់ជាតិ ស្តីពី អាជ្ញាកណ្តាល ចៅក្រម លើវិញ្ញាសា បាល់ទាត់ បាល់ទះ បាល់បោះ និង អត្តពលកម្ម ។
  - គ្រូអត្តពលកម្មចំនួន ០១នាក់ នៅវិទ្យាល័យពោធិ៍សាត់បានទទួលការបណ្តុះបណ្តាលស្តីពីគ្រូជំនួយអត្តពលកម្មកម្រិតអាស៊ីនៅសធារណរដ្ឋកូរ៉េ ។
  - មន្ត្រីអប់រំកាយ និងកីឡាចំនួន ០១នាក់បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី គ្រូកម្រិតថ្នាលកីឡាវាយសីថ្នាក់អាស៊ីនៅរាជធានីភ្នំពេញ។

-បញ្ហាប្រឈមទាក់ទងនឹងគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ
- ប្រសិទ្ធភាពនៃសេវាអប់រំ:
  - ខ្វះគ្រូអប់រំកាយ និងកីឡា
  - ទីលានសម្រាប់ហ្វឹកហ្វាត់អប់រំកាយ និងកីឡាមិនទាន់សមស្រប។
- គុណភាពនៃសេវាអប់រំ:
  - ការអនុវត្តន៍កម្មវិធីអប់រំកាយ និងកីឡា ២ម៉ោង ក្នុងមួយសប្តាហ៍មិនទាន់បានល្អសម្រាប់សាលាមិនគ្រប់កម្រិត និងសាលាបណ្តែតទឹក
  - ខ្វះគ្រូជំនាញអប់រំកាយ និងកីឡា
  - ខ្វះសម្ភារៈ

- មិនបានតម្រង់ទិសគ្រូអប់រំកាយ និងកីឡាលើការប្រើប្រាស់សៀវភៅសិក្សាគោល

## ខ.ឆានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

-ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានផ្តោតលើលទ្ធផល:

- សាលារៀនចំនួន ១៧៧ សាលា បានចុះពិនិត្យតាមដានលើសកម្មភាពបង្ហាត់ និង ហាត់ ។
- មន្ត្រីអប់រំកាយ និងកីឡាថ្នាក់ខេត្តបានចុះសហការរៀបចំប្រកួតកីឡាសិស្សជ្រើសរើសជើងឯកនៅក្រុង ស្រុកទាំង ០៦ ។
- បានរៀបចំប្រកួតកីឡាដណ្តើមពានរង្វាន់ផ្សេងៗចំនួន ១០ពាននៅក្រុងពោធិ៍សាត់ បាកាន កណ្តៀង ក្រគរ ភ្នំក្រវាញ។
- បានរៀបចំប្រកួតកីឡាមិត្តភាពចំនួន ៣២៥ លើក លើវិញ្ញាសា បាល់ទាត់ បាល់បោះ បាល់ទះក្នុងខេត្តពោធិ៍សាត់ ។
- មន្ត្រីចំនួន ៣៨ នាក់ ស្រី ០២ នាក់ ទទួលបានការបំប៉នសមត្ថភាពលើការងារបច្ចេកទេសកីឡាបាល់ទាត់នៅស្រុកភ្នំក្រវាញ ។

-ការអភិវឌ្ឍសមត្ថភាព

| សកម្មភាព | រយៈពេល | ទីកន្លែង | អ្នកចូលរួម | អ្នកឧបត្ថម្ភ |
|---|---|---|---|---|
| ១.វគ្គលេខាធិ និងស្ទង់ការប្រកួតកីឡាបាល់បោះ | ០៣ថ្ងៃ | រាជធានីភ្នំពេញ | ០៣ នាក់ | ថវិកាកម្មវិធី |
| ២.វគ្គបណ្តុះបណ្តាលអាជ្ញាកណ្តាល និចៅក្រមកីឡាអត្តពលកម្ម | ០៥ថ្ងៃ | ខេត្តកំពង់ឆ្នាំង | ០៣ នាក់ | ថវិកាកម្មវិធី |
| ៣.វគ្គបណ្តុះបណ្តាលអាជ្ញាកណ្តាល ចៅក្រមកីឡាបាល់ទះ | ០៦ថ្ងៃ | ខេត្តពោធិ៍សាត់ | ០៥ នាក់ | ថវិកាកម្មវិធី |
| ៤.សហការរៀបចំការប្រកួតកីឡាបាល់ទាត់ ដណ្តើមពានរង្វាន់យុវជន | ២ ថ្ងៃ | ស្រុកវាលវែង | ៤ នាក់ | របស់ការិ. |
| ៥.សិក្ខាសាលាផ្សព្វផ្សាយប្រដាល់គុណខ្មែរ | ២ ថ្ងៃ | រាជធានីភ្នំពេញ | ១ នាក់ | ថវិកាកម្មវិធីរបស់ការិ. |
| ៦.វគ្គវាយតម្លៃអាជ្ញាកណ្តាលប្រើប្រាស់ | ១ ថ្ងៃ | ខេត្តតាកែវ | ១ នាក់ | ថវិកាកម្មវិធីរបស់ការិ. |
| ៧.ប្រជុំស្តីពី កិច្ចប្រជុំណែនាំ | ១ ថ្ងៃ | រាជធានី | ៣ នាក់ | ថវិកាកម្មវិធី |

| | | | | |
|---|---|---|---|---|
| បទបញ្ញារួម និងបទបញ្ញាបច្ចេកទេស សម្រាប់ការប្រកួតកីឡាថ្នាក់ជាតិសិស្សបឋមសិក្សា និងមធ្យមសិក្សា ជ្រើសរើសជើងឯកទូទាំងប្រទេស | | ភ្នំពេញ | | |
| ៨.សិក្ខាសាលាស្ដីពីការដាក់ពាក្យចូលរួមប្រកួតកីឡាតាមប្រព័ន្ធព័ត៌មានវិទ្យា | ១ ថ្ងៃ | រាជធានីភ្នំពេញ | ៣ នាក់ | ថវិកាកម្មវិធីរបស់ការិ. |
| ៩.វគ្គបណ្ដុះបណ្ដាលអាជ្ញាកណ្ដាល និងអ្នកវាយតម្លៃអាជ្ញាកណ្ដាល | ៥ ថ្ងៃ | រាជធានីភ្នំពេញ. | ៤ នាក់ | ថវិកាកម្មវិធីឆ្នាំ២០១៧របស់ការិ. |
| ១០. បានចូលរួមសិក្ខាសាលាស្ដីពីគ្រូបាល់តាត់កម្រិតថ្នាល | ៤ ថ្ងៃ | ស្រុកភ្នំក្រវាញ | ៣៨ នាក់ | ថវិកាកម្មវិធីឆ្នាំ២០១៧របស់ការិ. |

## ៣.តារាងសូចនាករ និងចំណុចដៅរបស់អនុវិស័យ ឆ្នាំ២០១៧

| ល.រ | សូចនាករ | ជាក់ស្ដែង 2016-2017 | ចំណុចដៅ 2017-2018 | ជាក់ស្ដែង 2017-2018 | ស្ថានភាព |
|---|---|---|---|---|---|
| **គោលនយោបាយទី ១ ៖ ធានាការអប់រំប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា** | | | | | |
| ១ | ចំនួនគ្រូអប់រំកាយ និងកីឡាបណ្ដុះបណ្ដាលក្នុងមួយឆ្នាំ | 2 | 5 | 3 | ⬇ |
| ២ | **ទីលានកីឡា ចំនួន ០៤ បានកែលម្អ** | | | | |
| | - ទីលានបាល់ទាត់ | 5 | 3 | 5 | ⬆ |
| | - ទីលានបាល់ទះ | 0 | 7 | 2 | ⬇ |
| | - ទីលានបាល់បោះ | 1 | 1 | 0 | ⬇ |
| | - ទីលានអត្តពលកម្ម | 0 | 3 | 1 | ⬇ |
| **គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និង គ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់(បង្កើនសិទ្ធផលកីឡាករ កីឡាការិនីដើម្បីដណ្ដើមយកជ័យជំនះក្នុងការប្រកួតនានា)** | | | | | |
| ១ | ចំនួនមេដាយមាសទទួលបានពីការប្រកួតកីឡាថ្នាក់ជាតិ | 11 | 2 | 3 | ⬆ |

<u>*សម្គាល់:*</u> ⬆សម្រេចបានតាមចំណុចដៅ ➡ អាចទទួលយកបាន ⬇ សម្រេចមិនបានតាមចំណុចដៅ

**៤.បញ្ហាប្រឈម**

- ខ្វះទីលានសម្រាប់ហ្វឹកហាត់
- ខ្វះគ្រូជំនាញអប់រំកាយ និងកីឡា
- ខ្វះសម្ភារសម្រាប់ហ្វឹកហាត់

**៥.សេចក្តីសន្និដ្ឋាន**

ការងារអប់រំកាយ និងកីឡាក្នុងឆ្នាំសិក្សា ២០១៦-២០១៧ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយបានរៀបចំប្រកួតកីឡាសិស្សថ្នាក់កម្រង ក្រុង ស្រុក ខេត្ត កីឡាមហាជនថ្នាក់ខេត្ត ប្រកួតកីឡាពានរង្វាន់ផ្សេងៗ បានជាច្រើនកម្មវិធី ជាពិសេស រត់ចម្ងាយស្ទឹងពោធិ៍សាត់ និងប្រណាំងកង់ ប្រកួតជាមិត្តភាព ហើយបានដឹកនាំកីឡាសិស្ស-មហាជនចូលរួមប្រកួតកីឡាថ្នាក់ជាតិទទួលបានលទ្ធផលជាទីមោទន:ព្រមទាំងបានជួសជុល និងកែលម្អទីលានមួយចំនួន។

ទន្ទឹមនិងនេះ សកម្មភាពអប់រំកាយ និងកីឡា ក៏នៅមានចំនុចខ្វះខាត ដែលត្រូវកែលម្អបន្ថែមទៀតសម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ ។

**III.អនុសាសន៍/ទិសដៅ**

**១.អនុវិស័យការអប់រំកុមារតូច**

**អនុសាសន៍**

- ស្នើក្រសួងអន្តរាគមន៍ដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដើម្បីជំរុញការបង្កើតមត្តេយ្យសិក្សាសហគមន៍។
- ស្នើក្រសួងទំលាក់កញ្ចប់ថវិកា ឱ្យទាន់ពេលវេលាដើម្បីអនុវត្តសកម្មភាពឱ្យបានតាមផែនការ។
- ស្នើក្រសួងបើកវគ្គបំប៉នដល់លោកគ្រូ អ្នកគ្រូបឋមសិក្សាដែលស្ម័គ្រចិត្តបង្រៀនថ្នាក់មត្តេយ្យ។

**ទិសដៅ**

- ពង្រឹងការស្រង់ស្ថិតិកុមារ ដែលមានអាយុពី០-៥ឆ្នាំឱ្យបានចំនួន ១០០កន្លែង លើ ២៧២ កន្លែង (សាលា មណ្ឌល និងសហគមន៍) ។
- ចុះជួយលើការងារដឹកនាំ និងគ្រប់គ្រងរបស់នាយិកាសាលាមត្តេយ្យសិក្សាដាច់ដោយឡែកទាំង ១៨ សាលា។
- ចុះជួយការងារបច្ចេកទេសបង្រៀន និង រៀន និងផលិតសម្ភារឧបទេសដល់សាលាមត្តេយ្យសិក្សារដ្ឋនិងមត្តេយ្យសិក្សាសហគមន៍ចំនួន ៧០ សាលា។
- ពង្រីកសាលាមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍ឱ្យបានចំនួន ០៦ កន្លែង។

- ចុះជួយពង្រឹងប្រសិទ្ធិភាពនៃការប្រជុំលើកម្មវិធីអប់រំតាមផ្ទះឱ្យបាន ៥៦ ភូមិក្នុង ២០ ឃុំ។

## ២.អនុវិស័យការងារអប់រំនៅបឋមសិក្សា

### អនុសាសន៍

- សុំក្រសួងបំប៉នលើផ្នែកបច្ចេកទេសវិធីសាស្ត្របង្រៀន និងជំរុញលើការជួយសិស្សរៀនយឺត(បំប៉នស្របពេល)។
- សុំក្រសួងបំប៉ន នាយក នាយិកាមួយចំនួនទើបឡើងថ្មីឱ្យយល់ច្បាស់ពីការងារគ្រប់គ្រង និងការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃសាលារៀនដោយផ្អែកលើលទ្ធផល ក្នុងការអនុវត្តការងារប្រចាំថ្ងៃ។

### ទិសដៅ

- បង្កើនចំនួន និង ពង្រឹងសាលាកុមារមេត្រីកម្រិតមធ្យម និងកម្រិតអភិវឌ្ឍឱ្យបានពី ១៩៥ ទៅ ២១២ សាលា ។
- កាត់បន្ថយអត្រាត្រួតថ្នាក់មកត្រឹម៦ភាគរយនិងអត្រាបោះបង់មកត្រឹម៤ភាគរយ
- បង្កើនចំនួនសាលារៀនគ្រប់កម្រិតដែលមានអត្រាត្រួតថ្នាក់តិចជាង១០ភាគរយ
- អនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃសាលារៀនផ្អែកលើលទ្ធផលឱ្យបាន ១២៧ លើ ៣០១ សាលា។
- ចុះពិនិត្យតាមដានលើការបង្រៀននិងរៀនបាន ១៦៧ សាលា
- សាងសង់អគារសិក្សា ៥ ខ្នង ស្មើ ២៥ បន្ទប់

## ៣.អនុវិស័យអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

### អនុសាសន៍

- ក្រសួងជួយពង្រឹងសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅមធ្យម សិក្សាបឋមភូមិ ក៏ដូចជាទុតិយភូមិ
- ក្រសួងបង្កើនថវិកាសម្រាប់ជួសជុលកុំព្យូទ័រ ដែលឧបត្ថម្ភដោយអង្គការKAPE

### ទិសដៅ

- ពង្រឹងការអនុវត្តការងាររបស់គ្រូបន្ទុកថ្នាក់លើការចុះពិនិត្យតាមដានសិស្សប្រឈម បោះបង់ការសិក្សា
- ពង្រឹងសកម្មភាពបណ្ណាល័យនៅតាមសាលាមធ្យមសិក្សាដែលមានបណ្ណាល័យស្របតាមស្តង់ដាចំនួន ០៧ កន្លែង។
- ជំរុញដំណើរការពិសោធន៍វិទ្យាសាស្ត្ររបស់អគារធនធាននៅវិទ្យាល័យពោធិ៍សាត់។
- សិស្សមធ្យមសិក្សាបឋមភូមិ យ៉ាងតិច ១៥ ភាគរយ ទទួលបានអាហារូបករណ៍

សិស្សក្រីក្រ។

- ពង្រឹងការងារពិនិត្យតាមដានការរៀននិងបង្រៀន ឱ្យបានគ្រប់សាលាមធ្យមសិក្សាចំនួន ៥៩ សាលា។
- បន្តចុះពិនិត្យតាមដានលើការងារផ្តល់អាហារូបករណ៍សិស្សក្រីក្រចំនួន៣៦ សាលា។
- ជំរុញការបង្កើតក្លឹបសិក្សាគណិតវិទ្យានៅតាមវិទ្យាល័យទូទាំងខេត្តដោយសហការជាមួយសហគមន៍អ្នកគណិតវិទ្យាកម្ពុជានិងសហគមន៍អ្នកគណិតវិទ្យាសាខាខេត្តពោធិ៍សាត់។

## ៤.អនុវិស័យអប់រំក្រៅប្រព័ន្ធ

### អនុសាសន៍

- សុំឱ្យក្រសួងអប់រំផ្តល់ថវិកាកម្មវិធី ឱ្យបានឆ្លើយតបតាមតម្រូវការរបស់គម្រោង
- សុំឱ្យក្រសួងអប់រំផ្តល់ថវិកាសម្រាប់វគ្គបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពមន្រ្តីអប់រំក្រៅប្រព័ន្ធ
- សុំឱ្យក្រសួងអប់រំជួយអន្តរាគមន៍ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានវិធានការកម្រិតលក្ខខណ្ឌនៃការជ្រើសរើសកម្មករចូលធ្វើការត្រូវមាចំណេះដឹង (ចេះអាន ចេះសរសេរ ចេះ គិតលេខ)។
- សុំឱ្យនាយកដ្ឋានអប់រំក្រៅប្រព័ន្ធបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលាឱ្យបានមុនកាលបរិច្ឆេទនៃការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ។
- សុំឱ្យនាយកដ្ឋានអប់រំក្រៅប្រព័ន្ធបើកវគ្គបំប៉ន សិក្ខាសាលា ដល់រដ្ឋអំណាច ភូមិ ឃុំ លើកម្មវិធីអប់រំក្រៅប្រព័ន្ធ ដើម្បីងាយស្រួលក្នុងការសម្រេចបានផែនការ។
- សុំឱ្យនាយកដ្ឋានមានឥណទានកម្ចី សម្រាប់សិស្សដែលបានរៀនចប់ជំនាញមុខរបរក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ យកទៅប្រកបមុខរបរបន្ត។

### ទិសដៅ

- ចុះប្រជុំផ្សព្វផ្សាយដល់សហគមន៍ ក្រុមមុខសញ្ញា(ដល់តំបន់ដាច់ស្រយាល) បន្ថែមទៀតឱ្យយល់ច្បាស់ពីកម្មវិធីអប់រំក្រៅប្រព័ន្ធឱ្យបាន ១២ដងក្នុងស្រុកក្រុងទាំង ០៦។
- ពង្រឹងដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍១៩កន្លែង និង បណ្ណាល័យ ០១ កន្លែង។
- សាងសង់បន្ថែមមជ្ឈមណ្ឌលសិក្សាសហគមន៍ ១ និង បណ្ណាល័យ ១
- ជម្រុញការអនុវត្តកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ
- ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្មមាន ៩១៣នាក់

- ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូលមាន ៦០០នាក់
- ចំនួនកុមារដែលបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ ៣៧៥ នាក់
- ចំនួនអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ ៥១០នាក់

**៥.អនុវិស័យការអភិវឌ្ឍន៍យុវជន**

**អនុសាសន៍**

- សុំសាងសង់អាគារមជ្ឈមណ្ឌលយុវជនថ្នាក់ខេត្ត
- សុំក្រសួងចងក្រង និង ផ្តល់សៀវភៅជំនាញទន់ សម្រាប់ថ្នាក់ខេត្តអប់រំបន្តដល់ថ្នាក់ក្រុង ស្រុក
- សុំក្រសួងបន្តចុះជួយរៀបចំសកម្មភាព និងធ្វើផែនការសម្រាប់គណៈកម្មការប្រតិបត្តិក្រុមប្រឹក្សាយុវជន កុមារ តាមសាលាបឋម និង មធ្យមសិក្សា
- សុំក្រសួងជួយអន្តរាគមន៍ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលដល់យុវជន (វគ្គអេដស៍ក្រៅសាលា យុវជនស្ម័គ្រចិត្តក្រៅសាលា)
- ស្វែងរកការគាំទ្រសម្រាប់សកម្មភាពសង្គម និង សម្អាតបរិស្ថាន

**ទិសដៅ**

- បន្តធ្វើពលកម្មសម្អាតបរិស្ថានតាមទីសាធារណៈឱ្យបាន ០៩ដង
- បន្តចុះជួយរៀបចំគណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាយុវជន កុមារ និងរៀបចំឱ្យមានការប្រជុំ ធ្វើផែនការប្រចាំខែទៀងទាត់
- បន្តចុះអប់រំផ្សព្វផ្សាយអំពីសុខភាពអនាម័យ សុវត្ថិភាព ចំណីអាហារ វិជ្ជាសង្គ្រោះបឋម សុវត្ថិភាពចរាចរផ្លូវគោគដល់យុវជន កុមារតាមសាលារៀន
- បន្តចុះរៀបចំបង្កើតគណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាកុមារឱ្យបាន២៨០សាលា
- បន្តសាងសង់បង្គន់អនាម័យ និង ប្រព័ន្ធទឹកស្អាតបន្ថែមដល់សាលាដែលខ្វះ

**៦.អនុវិស័យអប់រំកាយ និង កីឡា**

**អនុសាសន៍**

- ស្នើក្រសួងបង្កើនការជ្រើសរើសគ្រូអប់រំកាយ និងកីឡាបន្ថែមទៀត ហើយជាបេក្ខជនដែលមានទីលំនៅក្នុងខេត្តរបស់ខ្លួនពិតប្រាកដ។
- ស្នើក្រសួងបន្តបើកវគ្គបំប៉នលើការងារបច្ចេកទេស និងអាជ្ញាកណ្តាលលើគ្រប់ប្រភេទកីឡា ។
- ស្នើក្រសួងបន្តផ្តល់សម្ភារកីឡាគ្រប់ប្រភេទ ដល់ខេត្តជារៀងរាល់ឆ្នាំ ។
- ស្នើក្រសួងបង្កើនកញ្ចប់ថវិកាសម្រាប់ជួសជុល និងកែលម្អទីលានកីឡា នៅតាមសាលារៀន ឬ ក្លិបកីឡា ។

**ទិសដៅ**

- ពិនិត្យសកម្មភាពបង្ហាត់ និងហាត់នៅតាមសាលារៀនឱ្យបានពី ១៥០សាលា
- ធ្វើតេស្តកាយសមស្របនិងតេស្តបច្ចេកទេសតាមសាលារៀនឱ្យបានពី៣៥សាលា
- ជំរុញក្រុង ស្រុក រៀបចំប្រកួតកីឡាសិស្សបឋម-មធ្យមសិក្សាជ្រើសរើសជើងឯកថ្នាក់ស្រុកឱ្យបានចំនួន ២១០ក្រុមចូលរួម។
- រៀបចំប្រកួតកីឡាសិស្ស និងមហាជនជ្រើសរើសជើងឯកថ្នាក់ខេត្តឱ្យបាន១៥០ក្រុមលើវិញ្ញាសា(បាល់ទាត់ , បាល់ទះ , បាល់បោះ និង អត្តពលកម្ម)
- សហការ និងរៀបចំប្រកួតកីឡាដណ្តើមពានរង្វាន់ផ្សេងៗឱ្យបាន០៦ពានរង្វាន់
- រៀបចំ និងសហការប្រកួតកីឡា បាល់ទាត់ ,បាល់ទះនិងបាល់បោះជាមិត្តភាពក្នុង និងក្រៅខេត្តឱ្យបាន ២០០លើក។
- ដឹកនាំកីឡាសិស្ស-មហាជនចំនួន ១៨ ក្រុម ទៅចូលរួមប្រកួតជាតិកីឡាថ្នាក់ជាតិ និងតាមកម្មវិធីរបស់សហព័ន្ធកីឡាជាតិនានា ឱ្យទទួលបានមេដាយមាសយ៉ាងតិច ០២ គ្រឿង ។
- បន្តជួសជុលនិងកែលម្អទីលានកីឡាគ្រប់ប្រភេទនៅតាមសាលារៀននិងសហគមន៍ឱ្យបាន ០៥កន្លែង និង ជួសជុល និងកែលម្អ ផ្លូវចូល និងទីលានបរិស្ថានក្នុងកីឡដ្ឋានខេត្ត។

**IV.សេចក្តីសន្និដ្ឋាន**

ពិនិត្យជារួមការងារអប់រំយុវជន និង កីឡាខេត្តពោធិ៍សាត់ មានការរីកចម្រើនគួរឱ្យកត់សម្គាល់លើផ្នែកហេដ្ឋារចនាសម្ព័ន្ធ សាលារៀនមានការកើនឡើង អាគារសិក្សាជាច្រើនខ្នងត្រូវបានសាងសង់ជំនួសអាគារសិក្សាចាស់ដែលទ្រុឌទ្រោម ពិសេសមត្តេយ្យសិក្សាដាច់ដោយឡែកបានប្រែក្លាយជាមត្តេយ្យធនធាន។ ដោយឡែកបើពិនិត្យទៅលើស្ថិតិយើងសង្កេតឃើញមានការកើនឡើងគ្រប់ភូមិសិក្សា(សិស្ស ថ្នាក់រៀន បុគ្គលិក.......) ប៉ុន្តែបើពិនិត្យទៅលើសូចនាករយើងសង្កេតឃើញថាសូចនាករមួយចំនួនសម្រេចបានតាមចំណុចដៅ ហើយសូចនាករមួយចំនួនអាចទទួលយកបាន និងសូចនាករមួយចំនួនទៀតមិនទាន់សម្រេចបានចំណុចដៅ។ លើបញ្ហានេះមន្ទីរអប់រំនឹងសហការជាមួយផ្នែកពាក់ព័ន្ធ ពិសេសដៃគូអភិវឌ្ឍន៍ក្នុងការចូលរួមដោះស្រាយបញ្ហាដែលនៅសេសសល់តាមរយៈយន្តការក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំខេត្តដើម្បីឱ្យវិស័យអប់រំក្នុងខេត្តមានការអភិវឌ្ឍកាន់តែប្រសើរឡើង។

**ថ្ងៃព្រហស្បតិ៍ ២កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១**

**ពោធិ៍សាត់,ថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៨**

**អ្នកធ្វើរបាយការណ៍**

**បានឃើញ និង ឯកភាព**

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡា**

**សុខ ដាលីន**

# កម្មវិធី
# សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំ សិក្សា ២០១៦ - ២០១៧
# និងលើកទិសដៅ ឆ្នាំសិក្សា ២០១៧ - ២០១៨
# ថ្ងៃទី ២៥ - ២៦ ខែ មករា ឆ្នាំ ២០១៨
# នៅបណ្ណាល័យសាមគ្គី វិទ្យាល័យពោធិ៍សាត់

ព្រឹកៈថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៨

| | |
|---|---|
| ៧:០០ | - សមាជិកសមាជិការនៃអង្គសន្និបាតអញ្ជើញដល់ |
| ៧:០០-៧:២០ | - ភ្ញៀវកិត្តិយសមន្ទីរនានាជុំវិញខេត្តអញ្ជើញដល់ |
| ៧:២០-៧:៤៥ | - គណៈអធិបតីអញ្ជើញដល់ |
| ៧:៤៥- ៩:០០ | ដំណើរការសន្និបាត<br>១- ប្រកាសហេតុ<br>២- ប្រកាសសមាសភាពគណៈអធិបតី<br>៣- គោរពទង់ជាតិ<br>៤- ទស្សនា របាំជូនពររបស់កុមារ<br>៥- សុន្ទរកថាស្វាគមន៍ដោយលោក **លី សុគន្ធី** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត<br>៦- ទស្សនា ឈុតខ្លីក្នុងរឿងម៉ាក់ថឹង<br>៧- សុន្ទរកថានិង មតិសំណេះសំណាលដោយ **ឯកឧត្តម ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្ត<br>៨- សុន្ទរកថា និង មតិសំណេះសំណាលបើកសន្និបាតដោយ **ឯកឧត្តម ថ្នាក់ដឹកនាំក្រសួង** |
| ៩:០០- ៩:១៥ | **សម្រាក និង រំសាយគណៈអធិបតី** |
| ៩:១៥-៩:៤៥ | - អានរបាយការណ៍បូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា កន្លងមកដោយ លោក **លឹម វុទ្ធី** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត<br>- អានទិសដៅសន្និបាតដោយ លោក **ចាន់ នី** អនុប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត |
| ៩:៤៥ -១១:៣០ | ១- បទបង្ហាញរបស់មត្តេយ្យសិក្សាឈើតុំ ស្រុកក្រគរ<br>ប្រធានបទ: ការងារគ្រប់គ្រង និង ដឹកនាំសាលា<br>២- បទបង្ហាញរបស់សាលាបឋមសិក្សាអូរតាប៉ោង ស្រុកបាកាន |

| | |
|---|---|
| | ប្រធានបទ: ការងារបង្រៀន និង រៀន<br>៣- បទបង្ហាញរបស់វិទ្យាល័យព្រះម្លូរ ស្រុកបាកាន<br>ប្រធានបទ: ការពង្រឹងគុណភាពអប់រំ<br>៤- បទបង្ហាញការងារអប់រំក្រៅប្រព័ន្ធ<br>ប្រធានបទ: កម្មវិធីសមមូលបឋមសិក្សា<br>៥- បទបង្ហាញរបស់អង្គការ Save The Children<br>ប្រធានបទ: គម្រោងកិច្ចសហប្រតិបត្តការរវាងដៃគូជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត |
| ១១:៣០-១:៣០ | **សម្រាកពិសារបាយថ្ងៃត្រង់** |
| **ល្ងាច ៖ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៨** | |
| ១:៣០-៣:៣០ | - ការពិភាក្សាពេញអង្គ តាមប្រធានបទ របស់អនុវិស័យទាំង០៦៖<br>**១.ការពិភាក្សា របស់អនុវិស័យអប់រំកុមារតូច**<br>- ប្រធានបទទី១: ការដឹកនាំនិងគ្រប់គ្រងសាលាមត្តេយ្យសិក្សារដ្ឋ<br>- ប្រធានបទទី ២ : ការដឹកនាំ និង គ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍<br>**២.ការពិភាក្សា របស់អនុវិស័យបឋមសិក្សា**<br>- ប្រធានបទទី ១: ការគ្រប់គ្រងតាមសាលារៀន<br>- ប្រធានបទទី ២: សាលាកុមារមេត្រីក្នុងបរិបទគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពគោលដៅទី៤ ( SDG4 )<br>**៣.ការពិភាក្សាអនុវិស័យមធ្យមសិក្សា**<br>- ប្រធានបទទី ១: ការគ្រប់គ្រងតាមសាលារៀន<br>- ប្រធានបទទី ២: ការរៀបចំស្តង់ដាសាលារៀនមធ្យមចំណេះទូទៅ<br>- ប្រធានបទទី ៣: ការអនុវត្តគោលនយោបាយ STEM<br>**៤.ការពិភាក្សាអនុវិស័យអប់រំក្រៅប្រព័ន្ធ**<br>- ប្រធានបទទី ១: ការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធក្នុងក្របខ័ណ្ឌការសិក្សាពេញមួយជីវិត<br>- ប្រធានបទទី ២: ការអភិវឌ្ឍកម្មវិធីសិក្សាអក្ខរកម្មឆ្លើយតប នឹងការអប់រំប្រកបដោយចីរភាព<br>**៥.ការពិភាក្សាអនុវិស័យការអភិវឌ្ឍយុវជន**<br>- ប្រធានបទទី ១: ការពង្រឹង និង ពង្រីកក្រុមប្រឹក្សាអភិវឌ្ឍន៍កុមារយុវជន នៅតាមគ្រឹះស្ថានសិក្សា |

| | |
|---|---|
| | - ប្រធានបទទី ២: ការពង្រឹង និង ពង្រីកមជ្ឍមណ្ឌលយុវជន នៅតាមមន្ទីរអប់រំ យុវជន និងកីឡា<br>**៦.ការពិភាក្សាអនុវិស័យអប់រំកាយនិងកីឡា**<br>- ប្រធានបទទី ១: កីឡាជាអនុវិស័យមួយរបស់ជាតិ<br>- ប្រធានបទទី ២: ការបណ្តុះថ្នាលនិស្សិតកីឡាឆ្ពោះទៅកីឡាស៊ីហ្គេមឆ្នាំ ២០២៣ |
| ៣:៣០-៣:៤៥ | **សម្រាកពិសារអាហារសម្រន់** |
| ៣:៤៥-៥:០០ | - ការបង្ហាញលទ្ធផលពិភាក្សាតាមអនុវិស័យនីមួយៗដោយថ្នាក់ដឹកនាំមន្ទីរ រយៈពេល ១០នាទីក្នុងមួយអនុវិស័យ |
| **ព្រឹក ៖ ថ្ងៃទី ២៦ខែ មករា ឆ្នាំ ២០១៨** | |
| ៧:០០- ៩:៣០ | - អនុសាសន៍របស់លោក ប្រធានមន្ទីរ និងអនុប្រធានមន្ទីរ អប់រំ យុវជន និងកីឡាខេត្ត ទទួលបន្ទុកតាមជំនាញ លើបញ្ហាពាក់ពន្ធ័អនុវិស័យទាំង ០៦ |
| ៩:៣០- ៩:៤៥ | **សម្រាកពិសារអាហារសម្រន់** |
| ៩:៤៥- ១១:៣០ | - មតិចូលរួមរបស់ការិយាល័យជំនាញទាំង ១១ របស់មន្ទីរ<br>- មតិចូលរួមរបស់សមាជិកក្នុងអង្គសន្និបាតទាំងមូល |
| **ល្ងាច ៖ ថ្ងៃទី ២៦ខែ មករា ឆ្នាំ ២០១៨** | |
| ១:៣០-៣:៣០ | - របាយការណ៍បូកសរុបលទ្ធផលសន្និបាតដោយលោក **លី សុគន្ធី**ប្រធានមន្ទីរអប់រំ យុវជននិងកីឡា |
| ៣:៤៥-៥:០០ | - មតិផ្តាំផ្ញើ និង ប្រកាសបិទអង្គសន្និបាតដោយ **ឯកឧត្តម បណ្ឌិត ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្ត<br>- គោរពភ្លេងជាតិ និង បិទកម្មវិធី |

☚*កំណត់សំគាល់* ៖ គណៈកម្មការរក្សាសិទ្ធិកែប្រែកម្មវិធីនេះក្នុងករណីចាំបាច់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តពោធិ៍សាត់**
**មន្ទីរអប់រំ យុវជន និងកីឡា**

**សុន្ទរកថាស្វាគមន៍**
**របស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**
**ក្នុងពិធីបើកការប្រជុំបូកសរុបការងារអប់រំ យុវជន និងកីឡា**
**ឆ្នាំសិក្សា ២០១៦-២០១៧ និងលើកទិសដៅឆ្នាំសិក្សា ២០១៧-២០១៨**

ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៨ នៅបណ្ណាល័យសាមគ្គីវិទ្យាល័យពោធិ៍សាត់

**សូមគោរព ៖**

-.......................................................................................................................

-.......................................................................................................................

-.......................................................................................................................

-ឯកឧត្តម លោកជំទាវ លោក លោកស្រីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត

-លោកគ្រូ អ្នកគ្រូ លោក លោកស្រី ប្រតិភូការិយាល័យអប់រំ យុវជន និងកីឡាគ្រប់ស្រុក

-អង្គសន្និបាតទាំងមូលជាទីមេត្រី

ថ្ងៃនេះ ជាទិវាប្រកបដោយនក្ខត្តឫក្ស ដែលយើងខ្ញុំទាំងអស់គ្នាជាមន្ត្រីរាជការ និងថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡា មានកិត្តិយសក្រៃលែងដោយបានទទួល ................................................................................................ ដែលបានឆ្លៀតឱកាសដ៏មមាញឹក និងមានតម្លៃ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០១៦-២០១៧ ដ៏ឱឡារិកនេះ ។

វត្តមានដ៏ឧត្តុង្គឧត្តមរបស់ លោកជំទាវ ពិតជាឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ខ្ពស់លើវិស័យ អប់រំ ដែលជាវិស័យអាទិភាពនៃគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល កម្ពុជាយ៉ាងពិតប្រាកដ ដែលធ្វើឱ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់មន្ទីរអប់រំ យុវជន និងកីឡា កាន់តែមានភាពកក់ក្តៅថែមមួយកម្រិតទៀតក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យអប់រំនៅក្នុងខេត្ត ក្នុងដំណាក់កាលថ្មី នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងបរិបទសហគមន៍អាស៊ាន និងសមាហរណកម្មក្នុងតំបន់ និងសកលលោក ។

ក្នុងពិធីដ៏មានអត្ថន័យនេះ ខ្ញុំក៏សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តមអភិបាលខេត្ត ឯកឧត្តម លោកជំទាវ លោក

លោកស្រី ជាភ្ញៀវកិត្តិយស ព្រមទាំងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដែលបានអញ្ជើញចូលរួមក្នុងសន្និបាតអប់រំប្រចាំឆ្នាំនេះ។

ទន្ទឹមនេះ ខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះការឧបត្ថម្ភគាំទ្រ គ្រប់បែបយ៉ាងពីសំណាក់ ឯឧត្តមអភិបាល ខេត្ត ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាការចូលរួមពីសហគមន៍ជាតិ អន្តរជាតិ ដៃគូរអភិវឌ្ឍ អាជ្ញាធរដែនដី សប្បុរសជន មាតាបិតា យុវជន និង សិស្សានុសិស្សទាំងអស់ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍វិស័យអប់រំ យុវជន និងកីឡាខេត្ត ឱ្យមានការរីកចម្រើនគួរជាទីមោទនៈ ។

-**ឯកឧត្តមគណៈអធិបតីជាទីគោរពដ៏ខ្ពង់ខ្ពស់**

-**អង្គសន្និបាតទាំងមូលជាទីមេត្រី** !

តាងនាមឱ្យមន្ទីរអប់រំ យុវជន និងកីឡា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអនុញ្ញាតរាយការណ៍ជូន ឯកឧត្តម និង អង្គសន្និបាតទាំងមូលជ្រាបពីសមិទ្ធិផលដែលមន្ទីរអប់រំ យុវជន និងកីឡា ដែលសម្រេចបានក្នុងឆ្នាំសិក្សា ២០១៦-២០១៧ កន្លងទៅនេះ បានឆ្លុះបញ្ចាំងពីការរីកចម្រើនថ្មីៗ ទាំងបរិមាណ ទាំងគុណភាព ធៀបទៅនឹងសកម្មភាព និង ចំណុចដៅដែលបានលើកឡើងកាលពីឆ្នាំកន្លងមក និងស្របតាមយុទ្ធសាស្ត្រនិងសូចនាករ ដែលបានកំណត់នៅក្នុង "ផែនការយុទ្ធសាស្ត្រ វិស័យអប់រំ " ៖

**១.ការងារអប់រំ**

ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំកសាងអគារសិក្សាជាច្រើននៅគ្រប់ច្រកល្ហកនៅទូទាំងប្រទេស ក៏ដូចជាខេត្តពោធិ៍សាត់ ពិសេស នៅតំបន់ដាច់ស្រយាល និង តំបន់ជួបការលំបាកក្នុងគោលដៅបង្វិតសាលារៀនឱ្យទៅជិតលំនៅស្ថានរបស់ប្រជាជន ស្រមតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

ជាលទ្ធផលនៅឆ្នាំសិក្សា ២០១៧-២០១៨ នៅទូទាំងខេត្តមានសាលារៀន ទាំងសាធារណៈ ឯកជន សហគមន៍ សរុប៥៣៩ រួមមាន ៖ សាលាមត្តេយ្យសិក្សា ១៦៩ កើនចំនួន ៣០ ។ សាលាបឋមសិក្សាចំនួន ៣០១ អនុវិទ្យាល័យចំនួន ៥៤ និង វិទ្យាល័យចំនួន ១៥ ។

តាមរយៈការធ្វើយុទ្ធនាការប្រមូលកុមារដល់វ័យសិក្សា ការសាងសង់អគារសិក្សា ការផ្តល់គ្រូបង្រៀន ការផ្តល់ថវិកាដំណើរការសាលារៀន ការផ្តល់អាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រជាពិសេស សិស្សនារីជាដើម បានបង្កលក្ខណៈឱ្យកុមារមានលទ្ធភាពទទួលបានការអប់រំ ។ បច្ចុប្បន្នអាត្រាពិតនៃការសិក្សារបស់កុមារនៅបឋមសិក្សាមាន ៩៨.៥ ភាគរយ(ស្រី៩៩.៦ភាគរយ) ។

សិស្សសរុបទូទាំងខេត្តនៅគ្រប់ភូមិសិក្សាសាធារណៈ និង ឯកជនពីមត្តេយ្យសិក្សាដល់មធ្យមសិក្សាសរុប ១០២,៣៥៨ នាក់ ស្រី ៥០,៨១៨ នាក់ ។ បុគ្គលិកអប់រំសរុបចំនួន ៤,០០៨ នាក់ ស្រី ១,៧៣៨ នាក់ ។ កម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន ៥៥ ថ្នាក់ មានគ្រូសរុប ៥៥ នាក់ ស្រី ២២ នាក់ សិស្សសរុប ១,០៩៥ នាក់ ស្រី ៧៣២ នាក់ ។ កម្មវិធីសមមូលបឋមសិក្សា: មាន ២៨ ថ្នាក់ មានគ្រូ ២៨នាក់ ស្រី ១១ នាក់ មានសិស្ស ៥៤៤ នាក់ ស្រី ២៦០ នាក់ ។ កម្មវិធីក្រោយអក្ខរកម្មក្នុងខេត្តពោធិ៍សាត់មានបណ្ណាល័យ ១ មណ្ឌលអានដាច់ដោយឡែក ១ មានអ្នកគ្រប់គ្រងសរុប ២ នាក់ ស្រី ០ នាក់ មានសិស្សចូលអាន២៣៤នាក់ ស្រី ៥៦ នាក់ ។ កម្មវិធីបង្កើនប្រាក់ចំណូលក្នុងខេត្តពោធិ៍សាត់ លើកលែងស្រុកវាលវែង មានមជ្ឈមណ្ឌលសិក្សាសហគមន៍ ១៩ កន្លែង មានគណៈគ្រប់គ្រង៩៥នាក់ ស្រី២០នាក់ ។ កម្មវិធីថ្នាក់បំពេញវិជ្ជាមធ្យមសិក្សាទុតិយភូមិ: មានចំនួន ៣ ថ្នាក់ មានគ្រូចំនួន ៥ ស្រី ០ នាក់ មានសិស្ស ១៤៩ នាក់ ស្រី ៣១ នាក់ ។

ក្នុងការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការផ្តល់សេវាអប់រំ មន្ទីរអប់រំ យុវជន និងកីឡា បានកែលម្អ និងដាក់ឱ្យអនុវត្តកម្មវិធីសិក្សាថ្មី និងផ្តល់សៀវភៅសិក្សា សម្ភារបច្ចេកទេស ដើម្បីបម្រើឱ្យការរៀន ការបង្រៀន និងការស្រាវជ្រាវនៅតាមគ្រឹះស្ថានសិក្សា និងបានយកចិត្តទុកដាក់ដល់ការងារតម្រង់ទិសវិជ្ជាជីវៈនៅតាមវិទ្យាល័យចំណោះទូទៅ ។

ទន្ទឹមនេះ មន្ទីរបានធ្វើវិក្រឹតការគ្រូបង្រៀនជាប្រចាំ ដើម្បីលើកកម្ពស់សមត្ថភាពគ្រូបង្រៀនដែលជាអ្នកផ្តល់ការអប់រំដល់យុវជនជំនាន់ក្រោយ ឱ្យកាន់តែមានចំណេះដឹង បំណិន និងសីលធម៌ខ្ពស់ ស្របតាមចតុស្តម្ភទាំងបួននៃការអប់រំគឺ "***រៀនដើម្បីមានចំណេះដឹង រៀនដើម្បីមានចំណេះធ្វើ រៀនដើម្បីក្លាយជាពលរដ្ឋល្អ និង រៀនដើម្បីចេះរស់នៅជាមួយគ្នា***" ព្រមទាំង បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងនៅគ្រប់កម្រិត ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ នៅក្នុងវិស័យអប់រំ ។ លើសពីនេះ យន្តការធានាគុណភាពអប់រំត្រូវបានរៀបចំ និងកំពុងអនុវត្តជាជំហានៗដើម្បី ពិនិត្យ និងវាយតម្លៃលើការសិក្សារបស់សិស្សានុសិស្ស និងការងារគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សាទូទាំងប្រទេស ។

**២.ការងារអភិវឌ្ឍយុវជន**

ការងារអភិវឌ្ឍយុវជន គឺជាកិច្ចការចម្បងចំពោះមុខ ដែលជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា រួមទាំងយុវជនខ្លួនឯងផងដែរ ដើម្បីជាការតបស្នងនិងបន្តវេនចំពោះប្រទេសជាតិ និងលើកមុខមាត់លើឆាកអន្តរជាតិ ។ មន្ទីរអប់រំ យុវជន និងកីឡា បានជំរុញលើកកម្ពស់សកម្មភាព និង សមត្ថភាពយុវជន ដោយសហការជាមួយនិងក្រសួងស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន អង្គការសង្គម ស៊ីវិល និង អង្គការអន្តរជាតិ ដើម្បីអប់រំ អាកប្បកិរិយាតាមរយៈកម្មវិធី "កូនល្អ សិស្សល្អ មិត្តល្អ " និងបង្កឱកាសបង្កើនការអប់រំជំនាញ និងអប់រំ

បច្ចេកទេស ជាពិសេស ដល់យុវជនក្រីក្រ យុវជនពិការ យុវជនជនជាតិ និង យុវជនងាយរងគ្រោះ ។

មន្ទីរបានពង្រឹង និងពង្រីកក្រុមប្រឹក្សាកុមារ យុវជន នៅតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត ដើម្បីបំពាក់បំប៉នជំនាញទន់ ការពង្រឹងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈរយៈពេលខ្លីដល់យុវជន និងការតម្រង់ទិសការសិក្សា និងការងារ ។ មន្ទីរបានពង្រឹងចលនាកាយរឹទ្ធិ ក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហមនៅតាមសាលារៀន និងបានប្រារព្ធទិវា ០១មិថុនា ខួបលើកទី៦៨ ។ សមាជិកកាយរឹទ្ធិទូទាំងខេត្តសរុប ៤០៥៦ នាក់ ស្រី ២០៤៨ នាក់ យុវជនកាកបាទក្រហម សរុប ២៧៥ នាក់ ស្រី ១៤០ នាក់ ។

**៣.ការងារអប់រំកាយ និងកីឡា**

ការងារអប់រំកាយ និងកីឡាមានការរីកចម្រើនគួរឱ្យកត់សំគាល់ ។ ការគាំទ្រលើវិស័យនេះកាន់តែមានកំណើនឡើង ដោយសារមហាជនមានការយល់ដឹង និងចាប់អារម្មណ៍លើការថែទាំសុខភាពតាមរយៈការហាត់ប្រាណជាប្រចាំ និងការលេងកីឡា ។ មន្ទីរអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធីសិក្សាអប់រំកាយ និងកីឡា សម្រាប់សាលាបឋមសិក្សាដែលជាថ្នាលគ្រឹះសម្រាប់អភិវឌ្ឍន៍កាយសម្បទា គំនិត ប្រាជ្ញា និងស្មារតីរបស់កុមារ និងបានរៀបចំការប្រកួតកីឡាសិស្សបឋមសិក្សា មធ្យមសិក្សាថ្នាក់កម្រង ក្រុង ស្រុក ខេត្ត និងប្រកួតកីឡាពានរង្វាន់ផ្សេងៗ បានជាច្រើនកម្មវិធី ជាពិសេស រត់ចម្ងាយស្ទឹងពោធិ៍សាត់ និងប្រណាំងកង់ ប្រកួតជាមិត្តភាព ហើយបានដឹកនាំកីឡាសិស្ស-មហាជនចូលរួមប្រកួតកីឡាថ្នាក់ជាតិទទួលបានលទ្ធផលជាទីមោទនៈ និងព្រមទាំងបានជួសជុល និងកែលម្អទីលានមួយចំនួន។

ទន្ទឹមនិងនេះ សកម្មភាពអប់រំកាយ និងកីឡា ក៏នៅមានចំនុចខ្វះខាត ដែលត្រូវកែលម្អបន្ថែមទៀតសម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ ។

-**ឯកឧត្តមគណៈអធិបតីជាទីគោរពដ៏ខ្ពង់ខ្ពស់**

-**អង្គសន្និបាតទាំងមូលជាទីមេត្រី**

ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងអប់រំ យុវជន និងកីឡាដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស ដោយបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ ផ្អែកលើបរិការណ៍ជាតិ និងអន្តរជាតិ ដូចជា ៖

-រៀបចំការងារអប់រំ យុវជន និងកីឡាជាអនុវិស័យចំនួន៧

-ផ្តល់ការអប់រំសម្បូរបែបឆ្លើយតបទៅនឹងតម្រូវការក្រុមមុខសញ្ញារៀនសូត្រ

-រៀបចំឱ្យមានគន្លងអាជីពសម្រាប់គ្រូបង្រៀន និងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

-កែទម្រង់វិស័យអប់រំ ១៥ ចំណុចដៅផ្តោតទៅលើសសរស្តម្ភទាំង៥ក្នុងការលើកកម្ពស់គុណភាពអប់រំ

-បន្ស៊ីគ្នារវាងក្របខណ្ឌការងារ និងពេលវេលា តាមរយៈការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងអង្គវិបស្សនាអប់រំ

-ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្រ្តកម្មវិធី សកម្មភាព សូចនាករនិងចំណុចដៅ ព្រមទាំងផែនការហិរញ្ញប្បទាន សម្រាប់ ២០១៦-២០២០

-ធ្វើការពង្រឹងបន្ថែមនូវប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃតាមអនុវិស័យនីមួយៗ ។

ដោយឡែកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បាននឹងកំពុងអនុវត្តផែនការយុទ្ធសាស្រ្តវិស័យអប់រំខេត្ត ដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់ដល់ការពង្រីកការអប់រំកុមារតូច ការបង្កើនលទ្ធភាពទទួលបានសេវាអប់រំនៅកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សាប្រកបដោយគុណភាពព្រមទាំងការពង្រីកការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍការងារយុវជន និង ការអប់រំកាយ និងកីឡា ដើម្បីផ្តល់ការយកចិត្តទុកដាក់លើការបំពេញការងារគណនេយ្យភាព និងលទ្ធផលច្បាស់លាស់ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល ។

ក្នុងន័យនេះ គោលបំណងនៃសន្និបាតអប់រំ យុវជន និងកីឡារយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី ២៥ ដល់ថ្ងៃទី២៦ ខែ មករា ឆ្នាំ ២០១៨ នឹងផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើការពិភាក្សាពេញអង្គឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីរកឱ្យឃើញបញ្ហាគន្លឹះនិងអនុសាសន៍នានាទាក់ទងនឹងប្រធានបទនៃ អនុវិស័យទាំង ៦ របស់ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៤-២០១៨ ដូចខាងក្រោម៖

**១.អនុវិស័យការអប់រំកុមារតូច**

ប្រធានបទទី១ ៖ ការគ្រប់គ្រងតាមសាលារៀន

ប្រធានបទទី២ ៖ ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍

**២.អនុវិស័យការអប់រំបឋមសិក្សា**

ប្រធានបទទី១ ៖ ការគ្រប់គ្រងតាមសាលារៀន

ប្រធានបទទី២ ៖ សាលាកុមារមេត្រីក្នុងបរិបទគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤

**៣.អនុវិស័យអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស**

ប្រធានបទទី១ ៖ ការគ្រប់គ្រងតាមសាលារៀន

ប្រធានបទទី២ ៖ ការរៀបចំស្តង់ដាសាលារៀនមធ្យមចំណេះទូទៅនិងមធ្យមសិក្សាបច្ចេកទេស

ប្រធានបទទី៣ ៖ ការអនុវត្តគោលនយោបាយ STEM

**៤.អនុវិស័យអប់រំក្រៅប្រព័ន្ធ**

ប្រធានបទទី១ ៖ ការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធក្នុងក្របខណ្ឌការសិក្សាពេញមួយជីវិត

ប្រធានបទទី២ ៖ ការអភិវឌ្ឍកម្មវិធីសិក្សាអក្ខរកម្មឆ្លើយតបនឹងការអប់រំក្របកដោយចីរភាព

**៥.អនុវិស័យការអភិវឌ្ឍយុវជន**

ប្រធានបទទី១ ៖ ការព្រងឹង និងពង្រីកក្រុមប្រឹក្សាអភិវឌ្ឍន៍កុមារ យុវជន នៅតាមគ្រឹះស្ថានសិក្សា

ប្រធានបទទី២ ៖ ពង្រឹងនិងពង្រីកមជ្ឈមណ្ឌលយុវជននៅតាមមន្ទីរអប់រំ យុវជន និងកីឡា

**៦.អនុវិស័យការអប់រំកាយ និងកីឡា**

ប្រធានបទទី១ ៖ កីឡាជាវិស័យអាទិភាពមួយរបស់ជាតិ

ប្រធានបទី២ ៖ ការបណ្តុះថ្នាលនិស្សិយកីឡាឆ្ពោះទៅកីឡាស៊ីហ្គេមឆ្នាំ ២០២៣ ។

ជាទីបញ្ចប់ តាងនាមមន្ទីរអប់រំ យុវជន និងកីឡា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្តងទៀត ចំពោះវត្តមានដ៏ថ្លៃថ្លារបស់ **ឯកឧត្តមអភិបាលនៃ គណៈអភិបាលខេត្ត** ដែលជានិច្ចជាកាលតែងយកចិត្តទុកដាក់ខ្ពស់ចំពោះវិស័យអប់រំ យុវជន និងកីឡា ក៏ដូចជាលោកគ្រូ អ្នកគ្រូ ។ ខ្ញុំក៏សូមថ្លែងអំណរគុណ និង សូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ដៃគូរអភិវឌ្ឍ ប្រតិភូអប់រំ យុវជន និងកីឡាក្រុង ស្រុក ព្រមទាំងមន្ត្រីអប់រំ យុវជន និងកីឡាគ្រប់លំដាប់ថ្នាក់សូមប្រកបដោយសុខភាពល្អ ថាមពលខ្លាំងក្លាប្រាជ្ញាឈ្លាសវៃ និង ទទួលបានជោគជ័យគ្រប់ ប្រការកុំបីអាក់ខានឡើយ ។ សូមប្រកបដោយពុទ្ធពរទាំង ៤ ប្រការ *គឺ* ***អាយុ វណ្ណៈ សុខៈ ពលៈ*** កុំបីឃ្លៀងឃ្លាតឡើយ ។ (អបអរសាទរ)

ក្នុងឱកាសថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នាមានកិត្តិយស និងរង់ចាំស្តាប់មតិសំណេះសំណាលរបស់ **ឯកឧត្តម** ដើម្បីទទួលបានអនុសាសន៍ដ៏ខ្ពង់ខ្ពស់សម្រាប់បន្តអនុវត្តន៍ភារកិច្ចឱ្យទទួលបានជោគជ័យបន្ថែមទៀត ។

**សូមអរគុណ**!